ប្រសិទ្ធភាព ហ្វាយនែន
Prasethpheap Finance

# របាយការណ៍ ប្រចាំឆ្នាំ ២០១៦



# មាតិកា


## ក ការវិវត្តអាជីវកម្ម

ទិន្នន័យសំខាន់ៗ ........ ០១
ទស្សនៈ បេសកកម្ម និងតម្លៃស្នូល ........ ០២
ព្រឹត្តិការណ៍សំខាន់ៗ ........ ០៥
ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ........ ០៨
ភាគទុនិក ........ ១២
ក្រុមប្រឹក្សាភិបាល ........ ១៣
គណៈគ្រប់គ្រង ........ ១៦
រចនាសម្ព័ន្ធគ្រប់គ្រង ........ ២០
សូចនករសំខាន់ៗ ........ ២១
ការត្រួតពិនិត្យផ្ទៃក្នុង ........ ២៣

## ខ អតិថិជន និងនិន្នាការសេដ្ឋកិច្ចសង្គម

ការបញ្ជាក់ពីអតិថិជន ........ ២៤
និន្នាការសេដ្ឋកិច្ចសង្គម ........ ២៧

## គ របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ៣០
របាយការណ៍របស់សវនករឯករាជ្យ ........ ៣៦
តារាងតុល្យការ ........ ៤០
របាយការណ៍លទ្ធផល ........ ៤២
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ........ ៤៣
របាយការណ៍លំហូរទឹកប្រាក់ ........ ៤៤

## ឃ អាសយដ្ឋានទាក់ទង

ស្នាក់ការកណ្តាល និងសាខា ........ ៤៦

...ធ្វើឱ្យជីវិតអ្នកកាន់តែប្រសើរ

*...Making Life Better*



# ការវិវត្តអាជីវកម្ម

| ទិន្នន័យសំខាន់ៗ | ខ្នាត | ២០១៦ | ២០១៥ | ២០១៤ |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធ | លានរៀល | ៤៤៧ | ៨២៧ | ៤១៨ |
| | ពាន់ដុល្លារ | ១១៨ | ២០៤ | ១០២ |
| សំពៀតឥណទាន | លានរៀល | ១២,០៤៦ | ១៣,៨៩១ | ៨,៤៤៨ |
| | ពាន់ដុល្លារ | ២,៩៨៣ | ៣,៤២៩ | ២,០៧៣ |
| ទ្រព្យសកម្មសរុប | លានរៀល | ១៥,៥២៥ | ១៥,៣២៤ | ១១,៧០១ |
| | ពាន់ដុល្លារ | ៣,៨៤៥ | ៣,៧៨៣ | ២,៨៧១ |
| មូលធនសរុប | លានរៀល | ១៣,២៦៩ | ១៥,៣២៤ | ៩,៧១០ |
| | ពាន់ដុល្លារ | ៣,២៨៧ | ៣,៧៨៤ | ២,៣៨៣ |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្មសរុប (ROA) | % | ៣,០៧% | ៥.៣៩% | ៣.៥៥% |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន (ROE) | % | ៣,៥៩% | ៥.៣៩% | ៤.២៨% |
| អនុបាតសោធនភាព (CAR) | % | ២៨,២៣% | ៨៥% | ៨៧% |
| ស្វ័យភាពគ្រប់គ្រាន់ផ្នែកប្រតិបត្តិការ (OSS) | % | ១៤១% | ១៨៥% | ១៦៧% |
| ស្វ័យភាពគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុ (FFS) | % | ១៣០% | ១៥៨% | ១៤៧% |
| សំពៀតឥណទានមានហានិភ័យធំជាង ៣០ ថ្ងៃ | % | ៤,៨១% | ៥.៤០% | ១១.៣៦% |
| សំពៀតឥណទានបាត់បង់ | % | ០,០៧% | 0% | 0% |
| ភាគរយអ្នកខ្ចីជាស្ត្រី | % | ៦៤,៥១% | ៦៨.៤៣% | ៦៦.១១% |
| បុគ្គលិកសរុប | | ៣៩ | ៣៧ | ៣១ |
| ចំនួនអ្នកខ្ចី | | ១១៣០ | ១៦៦៦ | ១២៦០ |
| ចំនួនខេត្តប្រតិបត្តិការ | | ៣ | ៣ | ៣ |
| ចំនួនស្រុកប្រតិបត្តិការ | | ៥៧ | ២៥ | ២៣ |
| ចំនួនភូមិប្រតិបត្តិការ | | ៣២៥ | ២០៣ | ១៥១ |
| ចំនួនអ្នកខ្ចីធៀបនឹងភ្នាក់ងារឥណទាន | | ៦៦ | ៩២ | ៨៤ |
| អត្រាប្តូរប្រាក់ | រៀលក្នុង ១ដុល្លារ | ៤,០៣៧ | ៤,០៥០ | ៤,០៧៥ |



# ទស្សនៈ បេសកកម្ម តម្លៃស្នូល

## ទស្សនវិស័យ

ធ្វើឱ្យជីវភាពប្រជាជនប្រសើរឡើង និងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។



## បេសកកម្ម

ផ្តល់សេវាកម្មហិរញ្ញវត្ថុដល់ប្រជាជន សហគមន៍ និងសហគ្រាសខ្នាតតូចនៅជនបទ និងទីប្រជុំជនប្រកបដោយនិរន្តរភាព។


តម្លៃស្នូល
ស្មោះត្រង់
ប្តេជ្ញាចិត្តខ្ពស់
តម្លាភាព
វិជ្ជាជីវៈ
យុត្តិធម៌
គុណធម៌
មានទំនួលខុសត្រូវ
ញញឹម

# ព្រឹត្តិការណ៍សំខាន់ៗ

- **ប្រសិទ្ធភាព ហ្វាយនែន** គឺជាគម្រោងមួយក្នុងចំណោមគម្រោងជាច្រើន របស់មូលនិធិ ម៉េងលីជេ.គួច ដែលជាមូលនិធិ មិនរកប្រាក់ចំណេញ ដោយធ្វើការងារជួយសង្គមលើគ្រប់វិស័យហើយដែលមូលនិធិ ម៉េងលី ជេ. គួច នេះគឺជាផ្នែកមួយរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន។

- **២០០៥** ប្រសិទ្ធភាព ហ្វាយនែន បានចាប់បដិសន្ធិនៅក្នុងឆ្នាំ២០០៥ ក្នុងគោលបំណងផ្ដល់ប្រាក់កម្ចីឥតការប្រាក់ដល់ បុគ្គលិក សិស្សានុសិស្ស និងប្រជាពលរដ្ឋទីទ័លក្រ និងប្រជាជនគ្រប់ស្រទាប់វណ្ណៈដែលកំពុងជួបការលំបាក។ ប្រសិទ្ធភាព ហ្វាយនែន បានផ្ដល់ប្រាក់កម្ចីជាង ៣,០០០,០០០ ដុល្លារ អាមេរិក (បីលាន-ដុល្លារអាមេរិក) ជូនដល់ បុគ្គលិក សិស្សានុសិស្ស និងប្រជាពលរដ្ឋ ចាប់តាំងពីមូលនិធិមួយនេះបានដំណើរការ។

- **២០១៣** ដើម្បីសម្រេចទស្សនវិស័យរបស់ខ្លួន "ធ្វើឲ្យជីវិតកាន់តែប្រសើរឡើង" ប្រសិទ្ធភាព ហ្វាយនែន បានធ្វើកំណែទម្រង់ ទៅជាអង្គការហិរញ្ញវត្ថុវិញនៅក្នុងឆ្នាំ២០១៣ ដែលផ្ដល់ប្រាក់កម្ចីជាមួយអត្រាការប្រាក់ទាប ជូនដល់សាធារណជនគ្រប់ស្រទាប់វណ្ណៈដើម្បីរក្សាឲ្យបាននូវនិរន្តរភាពរបស់ខ្លួន ហើយនាពេលបច្ចុប្បន្ននេះ ប្រសិទ្ធភាពហិរញ្ញវត្ថុ គឺជាអង្គភាពដាច់ដោយឡែកពីមូលនិធិម៉េងលី ជេ. គួច។ ប្រសិទ្ធភាព ហ្វាយនែន បានសន្យានិងប្ដេជ្ញាចិត្ត ធ្វើការជាគ្រឹះស្ថាន ហិរញ្ញវត្ថុដែលរឹងមាំក្នុងការផ្ដល់ប្រាក់កម្ចី ដើម្បីបង្កើតឱកាសធ្វើឱ្យប្រជាជនមានជីវភាពធូរធារ និងចម្រើនលូតលាស់ ជាចលករមួយក្នុងការចូលរួមអភិវឌ្ឍប្រទេសកម្ពុជា។ ប្រសិទ្ធភាព ហ្វាយនែន ប្រកាន់ភ្ជាប់នូវគោលការណ៍នៃភាពស្មើគ្នាក្នុងឱកាសការងារ និងសមត្ថភាពការងារ។

- **២០១៦** ប្រសិទ្ធភាព ហ្វាយនែន បានទទួលអាជ្ញាបណ្ណ ប្រកបអាជីវកម្មជាផ្លូវការពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១៦ ដែលមានលេខសម្គាល់ ម.ហ ៧៣ ហើយយើងបានប្រែក្លាយមកជា "ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី" ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មី ដោយបានដាក់ប្រកាសសម្ពោធជាផ្លូវការនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ប្រធានក្រុមប្រឹក្សាភិបាល នៃប្រសិទ្ធភាព ហ្វាយនែន ជាមួយការវិនិយោគសរុបជាទឹកប្រាក់ចំនួន ៣,៨១៧,១៩២ ដុល្លារអាមេរិក ដែលនេះគឺជាការបង្កើតឡើងដោយភាគទុនិកខ្មែរ ១០០%៕




# Mengly J. Quach Foundation







*សន្និសីទស្តីពី ប្រសិទ្ធភាព ហ្វាយនែន ទទួលបានអាជ្ញាបណ្ណអាជីវកម្ម*

# ចំណាប់អារម្មណ៍របស់
# ប្រធានក្រុមប្រឹក្សាភិបាល



ប្រសិទ្ធភាព ហ្វាយនែន ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលបង្កើតឡើង ដោយភាគទុនិកខ្មែរ ១០០% និងទទួលបាន អាជ្ញាបណ្ណប្រកបអាជីវកម្ម មីក្រូហិរញ្ញវត្ថុជាផ្លូវការកាលពីចុងខែសីហា ឆ្នាំ២០១៦ កន្លងទៅនេះ។ ដើមឡើយនៅក្នុងឆ្នាំ ២០០៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន គ្រាន់តែជាគម្រោងមួយរបស់មូលនិធិ ម៉េងលី ជេ.គួច ប៊ុណ្ណោះ ដែល ផ្តល់ប្រាក់កម្ចីដោយមិនគិតការប្រាក់ក្នុងទំហំទឹកប្រាក់ ជាង៣លានដុល្លារ រួចមកហើយ ដល់បុគ្គលិកសិស្សានុសិស្ស និង ប្រជាជនក្រីក្រ។ ដោយសារតែមើលឃើញថា គ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុ ភាគច្រើនមានវិនិយោគិនជាជនជាតិបរទេស ដែលបាននាំយកប្រាក់ចំណេញទៅប្រទេសគេវិញ ទើបក្នុងនាមខ្ញុំ ជាកូនខ្មែរមួយរូប ខិតខំបង្កើតស្ថាប័នមួយជារបស់ខ្មែរ ដែលល្អប្រសើរនៅក្នុងប្រទេសកម្ពុជា និងទទួលស្គាល់ជា អន្តរជាតិ។ ការផ្តល់ឥណទានរបស់ប្រសិទ្ធភាព ហ្វាយនែន នឹងមានការប្រាក់ទាប ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ធៀបជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃទៀត

ហើយការផ្តល់ឥណទានរបស់យើង ត្រូវបានសិក្សាពិនិត្យដោយហ្មត់ចត់ ធ្វើឲ្យប្រជាពលរដ្ឋដែលទទួលបានប្រាក់កម្ចីអាចយកទៅប្រើប្រាស់បានសមស្រប និងមិនក្លាយជាបំណុលវ័ណ្ឌកសម្រាប់គ្រួសាររបស់ពួកគាត់។ នៅក្នុងឆ្នាំ២០១៦ ប្រសិទ្ធភាព ហ្វាយនែន រក្សាបានកំណើនគួរឱ្យកត់សម្គាល់តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុច្រើនប្រភេទដល់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និងសហគ្រាសខ្នាតតូចបំផុតតូច និងមធ្យមនៅកម្ពុជា ប្រកបដោយនិរន្តរភាព និងទំនួលខុសត្រូវខ្ពស់។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៦ ប្រសិទ្ធភាព ហ្វាយនែន បានផ្តល់សេវាជូនអតិថិជនប្រមាណជាង ១,១៣០ នាក់ នៅតាមបណ្តាញសាខាចំនួន ២កន្លែង ហើយប្រសិទ្ធភាព ហ្វាយនែន នៅតែបន្តពង្រីកបណ្តាញរបស់ខ្លួនដើម្បីផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយដល់អតិថិជននៅក្នុងប្រទេសកម្ពុជា។ ទាក់ទងនឹងសមិទ្ធផលប្រតិបត្តិការប្រសិទ្ធភាព ហ្វាយនែន បានសម្រេចលើសផែនការ ដែលឈានដល់ការរីកចម្រើនគួរឱ្យកត់សម្គាល់ សម្រាប់សំពៀតឥណទានមានការកើនឡើងចំនួន ១៦% គិតជាតួលេខ។ ប្រសិទ្ធភាព ហ្វាយនែន បានធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រឥណទានរបស់ខ្លួនឱ្យស្របតាមទីផ្សារ ដែលជាតម្រូវការដ៏ច្រើនពីសហគ្រិនខ្នាតតូច និងប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលមធ្យមនៅកម្ពុជា។ ជាលទ្ធផលទំហំប្រាក់កម្ចីជាមធ្យមបានកើនឡើងប្រមាណ ៤៣%។ ប្រសិទ្ធភាព ហ្វាយនែន នៅតែបន្តយកចិត្តទុកដាក់ក្នុងការធ្វើពិពិធកម្ម ផលិតផលឥណទានចម្រុះជាមួយនឹងការកើនឡើងនៃទំហំសំពៀត ឥណទានខ្នាតូច និងមធ្យម រួមជាមួយឥណទានកសិកម្ម។ ការគ្រប់គ្រងហានិភ័យឥណទានបានល្អគឺជាកត្តាជួយ ជ្រោមជ្រែងស្ថាប័នឲ្យរក្សាបាននូវកម្រិតគុណភាពផលបត្រប្រាក់កម្ចីល្អប្រសើរ ដែលក្នុងនោះមក្រិតហានិភ័យ៣០ថ្ងៃមានអត្រាប្រមាណត្រឹមតែ ១% ប៉ុណ្ណោះ នៅដំណាច់ឆ្នាំនេះ។ ចំណែកឯលទ្ធផលហិរញ្ញវត្ថុវិញ យើងទទួលបានផលវិជ្ជមាន ដោយក្នុងនោះមានការទទួលបានផលចំណេញធៀបនឹងដើមទុនប្រមាណ ៤% នេះដោយសារតែមានការត្រួតពិនិត្យគ្រប់គ្រងយ៉ាងហ្មត់ចត់ត្រឹមត្រូវទៅលើចំណាយប្រតិបត្តិការ និងហានិភ័យ។ នាឆ្នាំ២០១៧ ខាងមុខ ប្រសិទ្ធភាព ហ្វាយនែន មាន គោលបំណងពង្រឹងផលិតភាព សមត្ថភាព និងប្រតិបត្តិការក៏ដូចជាពង្រីកបន្ថែមនូវបណ្តាញសាខារបស់ខ្លួនចំនួន ២ បន្ថែមទៀតដើម្បីគាំទ្រដល់តម្រូវការរបស់ប្រជាពលរដ្ឋ និងរួមចំណែកកសាងសេដ្ឋកិច្ចជាតិឱ្យបានរីកចម្រើន។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណ ចំពោះបុគ្គលិក ប្រសិទ្ធភាព ហ្វាយនែន ទាំងអស់ និងថ្នាក់គ្រប់គ្រងគ្រប់ជាន់ថ្នាក់ដែលបានខិតខំប្រឹងប្រែងរហូតសម្រេចបានលទ្ធផលដ៏ល្អប្រសើរ។ ទាំងនេះគឺជាការខិតខំបំពេញការងារ និងការប្តេជ្ញាចិត្តខ្ពស់របស់បុគ្គលិក និងថ្នាក់គ្រប់គ្រងដែលធ្វើឱ្យប្រសិទ្ធភាព ហ្វាយនែន រីកចម្រើនរហូតមកដល់សព្វថ្ងៃនេះ។ យើងទាំងអស់គ្នាប្តេជ្ញាបន្តវប្បធម៌សហការគ្នាទៅអនាគតដើម្បីធានាថា គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន នឹងនៅតែជាស្ថាប័ន ដែលមានការទទួលខុសត្រូវខ្ពស់ តាមរយៈការផ្តល់ជូននូវសេវាហិរញ្ញវត្ថុ ដែលមានតម្លៃសេវាទាប និងសមស្របជូនប្រជាពលរដ្ឋកម្ពុជា៕


Making Life Better



**ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី**

ប្រធានក្រុមប្រឹក្សាភិបាល

# ភាគទុនិក

| ល.រ | ឈ្មោះ | ភាគហ៊ុនសរុប | ចំនួនហ៊ុនសរុប | ភាគហ៊ុនសរុប គិតជាភាគរយ |
|---|---|---|---|---|
| ១ | ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ៩៤៩,២០០.០០ | ៩៤៩,២០០.០០ | ៩៤.៩២% |
| ២ | ភី អេហ្វ អេស អេ ភីអិលស៊ី | ៥០,៨០០.០០ | ៥០,៨០០.០០ | ៥.០៨% |
| | **សរុប** | ១,០០០,០០០.០០ | ១,០០០,០០០.០០ | ១០០.០០% |

# ប្រាក់កម្ចី

| ល.រ | ប្រភពប្រាក់កម្ចី | ឥណទានទទួលបាន (គិតជាប្រាក់ដុល្លារ) | សមតុល្យឥណទាន | អត្រាការប្រាក់ ប្រចាំឆ្នាំ | រយៈពេល ឥណទាន |
|---|---|---|---|---|---|
| ១ | ឥណទានិកក្នុងស្រុក | ២០០,៤៣២.០០ | ២០០,៤៣២.១០ | ១២% | ១២ខែ |
| ២ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣០០,០០០.០០ | ៧៥,៣៦២.៥៩ | ៩% | ៣៦ខែ |
| ៣ | ធនាគារ អភិវឌ្ឍន៍ជនបទ | ៣០០,០០០.០០ | ២៧៧,៦៤៨.៩២ | ៩% | ៣៦ខែ |
| | **សរុប** | ៨០០,៤៣២.១០ | ៥៥៣,៤៤៣.៦១ | | |




# ក្រុមប្រឹក្សាភិបាល

លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ដែលមានសញ្ជាតិខ្មែរ-អាមេរិក គឺជាអ្នកឯកទេសខាងអប់រំ ជាជនស្នេហាជាតិ និងជាសហគ្រិនមួយរូប។ បច្ចុប្បន្ននេះ គាត់ត្រូវបានគេស្គាល់ថា ជាស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ដែលជាស្ថាប័នផ្តល់សេវាអប់រំឈានមុខគេនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត លោកគឺជា ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី។ ចាប់តាំងពីត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានពង្រីកខ្លួនបាន បួនសាខា នៅតាមបណ្តាខេត្ត/ក្រុងផ្សេងៗគ្នា។

លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី បានសិក្សានៅសាកលវិទ្យាល័យ Berkeley រដ្ឋ California សហរដ្ឋអាមេរិក ដែលជាកន្លែងលោកបានបញ្ចប់ការសិក្សាផ្នែក Pre-Med Studies នៅឆ្នាំ ១៩៩១។ លោកក៏បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Spartan Health Sciences នៃរដ្ឋ New Mexico សហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៩៨ ដោយទទួលបានសញ្ញាបត្រផ្នែកវេជ្ជបណ្ឌិតវេជ្ជសាស្ត្រ ជំនាញវេជ្ជសាស្ត្រទូទៅផងដែរ។ លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី បានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកសុខភាពសាធារណៈ ក្នុងឆ្នាំ ២០០៧ ពីសាកលវិទ្យាល័យ Massachusetts Amherst ក្នុងក្រុង Amherst រដ្ឋ Massachusetts សហរដ្ឋអាមេរិក។ លោកក៏បានធ្វើការជាគ្រូវិទ្យាសាស្ត្របង្រៀននៅ ដេប៉ាតឺម៉ង់ វិទ្យាសាស្ត្រស្តីពីរូបរាងកាយ និងជីវិតនៃមហាវិទ្យាល័យ Cleveland Chiropractic ក្នុងក្រុង Los Angelesរដ្ឋ California អស់ មួយរយៈពេលមុនពេលដែលលោកវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញក្នុងឆ្នាំ២០០២ ក្នុងនាមជាអ្នកប្រឹក្សាយោបល់នៃគម្រោង "Integrated Management of Childhood Illness" (IMCI) និងសុខភាពសាធារណៈរបស់អង្គការ "ដៃគូដើម្បីអភិវឌ្ឍ" ដែលមានមូលដ្ឋាននៅរដ្ឋ Maryland សហរដ្ឋអាមេរិក។ ក្រោយមក លោកបានកាន់តំណែងជាសាស្ត្រាចារ្យរង ផ្នែកវិទ្យាសាស្ត្រ

សុខាភិបាល នៃមហាវិទ្យាល័យ គណិតសាស្រ្ត វិទ្យាសាស្រ្ត និងវិស្វកម្ម នៅសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា ហើយលោកក៏បានកាន់តំណែងជាស្ថាបនិក ព្រឹទ្ធបុរស និងជាសាស្រ្តាចារ្យរង ផ្នែកសុខភាពសាធារណៈនៃមហាវិទ្យាល័យសុខភាពសាធារណៈ នៅសាកលវិទ្យាល័យកម្ពុជា មុនពេលលោកបង្កើត ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន នាឆ្នាំ២០០៥។ លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ត្រូវគេទទួលស្គាល់ចំពោះការចូលរួមយ៉ាងសកម្ម នៅក្នុងការអភិវឌ្ឍសហគមន៍ តាមរយៈការខិតខំប្រឹងប្រែងរបស់លោកក្នុងវិស័យអប់រំ វិស័យសុខាភិបាល និងការបម្រើសេវាសង្គម។

**ពានរង្វាន់កិត្តិយសចុងក្រោយ ដែលលោកទទួលបានមានដូចខាងក្រោម៖**

- អ្នកដឹកនាំអាជីវកម្មឆ្នើមប្រចាំឆ្នាំ២០១៦, ពាណិជ្ជកម្មកម្ពុជា, ចេញផ្សាយខែធ្នូ ឆ្នាំ២០១៦
- អ្នកដឹកនាំអាជីវកម្មឆ្នើមប្រចាំឆ្នាំ២០១៥, ពាណិជ្ជកម្មកម្ពុជា, ចេញផ្សាយខែធ្នូ ឆ្នាំ២០១៥
- ចំណាត់ថ្នាក់លេខ២ ពានរង្វាន់ "សប្បុរសជនដ៏អស្ចារ្យទាំង៥" ប្រចាំឆ្នាំ២០១៥, គេហទំព័រសប្បាយ, ព្រះរាជាណាចក្រកម្ពុជា ២០១៥
- ពានរង្វាន់អ្នកដឹកនាំឆ្នើមក្នុងនាមជាដៃគូអប់រំ ប្រគល់ដោយសមាគម Worlddidac ក្នុងសន្និសីទថ្នាក់តំបន់អាស៊ីរបស់ Worlddidac ប្រចាំឆ្នាំ២០១៥ នៅឯក្រុងហុងកុង ឆ្នាំ២០១៥

**តួនាទីផ្សេងៗ នាពេលបច្ចុប្បន្នរបស់លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី រួមមានដូចខាងក្រោម៖**

- ទីប្រឹក្សាកិត្តិយស នៃសមាគមសហគ្រិនស្រ្តីកម្ពុជា ចាប់តាំងពីឆ្នាំ២០១៦
- សមាជិកក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព, ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០១៤
- សមាជិកស្ថាបនិក និងទីប្រឹក្សា នៃក្លឹបអ្នកវិនិយោគកម្ពុជា, ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០១៣
- សមាជិកទីប្រឹក្សា នៃសភាពាណិជ្ជកម្មកម្ពុជា, ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០១១
- ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាន នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី, ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០១០
- ទីប្រឹក្សាប្រធានកាយរិទ្ធកម្ពុជា នៃឯកឧត្តម សុខ អាន, អនុរដ្ឋមន្រ្តី រដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី និងជាប្រធានកាយរិទ្ធកម្ពុជា, ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០១០
- ទីប្រឹក្សាទីស្តីការគណៈរដ្ឋមន្រ្តី នៃរាជរដ្ឋាភិបាលកម្ពុជា (មានឋានៈស្មើអនុរដ្ឋលេខាធិការ), ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០១០
- ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច គ្រុប (ម៉េងលី ជេ គួច អេឌ្យូខេសិន, សេវាសុខភាព ម៉េងលី ជេ. គួច, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី និង មូលនិធិម៉េងលី ជេ. គួច), ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០០៥
- ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន (វិទ្យាស្ថានអន្តរទ្វីប អាមេរិកាំង, សាលារៀន អន្តរទ្វីប អាមេរិកាំង, សេវាដឹកជញ្ជូន អន្តរទ្វីប, ផលិតកម្ម ម៉េងលី ជេ. គួច, ម៉េងលី ជេ. គួច ឌីវីឡុបមិន, ម៉េងលី ជេ. គួច មេឌា, អាហារដ្ឋាន ផល គួច), ព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ២០០៥។

## លោក **លាក់ វាសនា**



បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិត ផ្នែករដ្ឋបាលសាធារណៈ ក្នុងឆ្នាំ២០១២ និងបរិញ្ញាបត្រផ្នែកបង្រៀនភាសាអង់គ្លេស ជាភាសាបរទេសក្នុងឆ្នាំ២០០៥។ លោកធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងជំនាញប្រតិបត្តិការ និងការគ្រប់គ្រង។ លោកក៏មានបទពិសោធការងារនៅក្នុងវិស័យអប់រំ និងវិស័យផ្សេងៗទៀតជាច្រើនចាប់តាំងពីឆ្នាំ ២០០៥។ លោកត្រូវបានដំឡើងតំណែង តួនាទីផ្សេងៗជាច្រើនទៀត ដូចជាជំនួយការអ្នកសម្របសម្រួលកម្មវិធីសិក្សា ជាជំនួយការអ្នកចាត់ការទូទៅ អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងជាអគ្គនាយករងកិច្ចការរដ្ឋបាល។

## លោក **កុង ហេមជន្ទ**



លោកបានចាប់ផ្តើមសហការ និងចូលរួមជាមួយប្រសិទ្ធភាព ហ្វាយនែន ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៤មក។ លោកមានបទពិសោធជាច្រើនទាក់ទងទៅនឹងកិច្ចការ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ដែលលោកធ្លាប់ធ្វើការឱ្យដូចជា ក្រុមហ៊ុនអាជីវកម្មជួញដូរ រោងចក្រ កសិដ្ឋាន និងតាមសាលារៀនធំៗតាំងពីឆ្នាំ២០០២ ហើយទទួលបានតួនាទី និងមុខតំណែង ដូចជា នាយកប្រតិបត្តិ រដ្ឋបាល និងគណនេយ្យ ជាអ្នកគ្រប់គ្រងលើគណនេយ្យករជាន់ខ្ពស់ និងជាអគ្គនាយកប្រតិបត្តិការហិរញ្ញវត្ថុ។ លោកធ្លាប់បានឆ្លងកាត់ការបំពេញការងារនៅតាមក្រុមហ៊ុនធំៗមួយចំនួនដូចជា ក្រុមហ៊ុន អ-អឹម-អេ ខេមបូឌា ក្រុមហ៊ុន ជីបម៉ុងគ្រុប, ក្រុមហ៊ុន អឹមអេច ប៊ីយ៉ូ អិនណឺជីគ្រុប, ក្រុមហ៊ុន ដូនពេញ ខេមបូឌាគ្រុប និងក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន។ លោកបានបញ្ចប់ការសិក្សាមក្រិតបរិញ្ញាបត្រ ផ្នែកគណនេយ្យ និងកំរិតអនុបណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម។ លោកក៏ធ្លាប់បានសិក្សាបញ្ចប់យ៉ាងជោគជ័យនូវវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា ជាច្រើនទៀតដូចជាការចាត់ចែងហិរញ្ញវត្ថុ និងការគ្រប់គ្រងផែនការហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលទាក់ទងនឹងការគ្រប់គ្រង និងភាពជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាពផងដែរ។

# គណៈគ្រប់គ្រង



## លោក **ម៉ុក ណាច**

អគ្គនាយកប្រតិបត្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន

លោក ម៉ុក ណាច កើតនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៨២ បានចូលធ្វើការជាមួយនឹង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន តាំងពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងតំណែងជាប្រធានឯករាជ្យ និងអគ្គនាយកប្រតិបត្តិ។ គាត់មានបទពិសោធយ៉ាងច្រើននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុតាំងពីឆ្នាំ២០០៦ នៅក្នុងតួនាទីជាច្រើនដូចជាមន្ត្រី ឥណទាន សវនករផ្ទៃក្នុង ប្រធាននាយកដ្ឋានប្រតិបត្តិការ អគ្គនាយករង ហើយចុងក្រោយជាអគ្គនាយកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន នៅក្នុងខែកក្កដា ឆ្នាំ២០១៤។ គាត់បានធ្វើការនៅក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនដូចជា ប្រាសាក់ ប្រតិបត្តិករឥណទានជនបទ CDA និងបច្ចុប្បន្នជាអគ្គនាយកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន។ គាត់ទទួលបានបរិញ្ញបត្ររងផ្នែកធនាគារបរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងអនុបណ្ឌិតផ្នែកគ្រប់គ្រង។ គាត់បានចូលរួមការបណ្តុះបណ្តាល និងសិក្ខាសាលាប្រកបដោយជោគជ័យជាច្រើនដូចជាការគ្រប់គ្រងដំណើរការ ការគ្រប់គ្រងផ្ទៃក្នុង សវនកម្មផ្ទៃក្នុង ការគ្រប់គ្រងឥណទានប្រាក់សន្សំ ការគ្រប់គ្រងហានិភ័យ ភាពជាអ្នកដឹកនាំ និងជំនាញគ្រប់គ្រង។



## លោក **គឹម ទេវិន្ទ្រ**
អគ្គនាយកផ្នែកហិរញ្ញវត្ថុ

លោក គឹម ទេវិន្ទ្រ បានចូលបម្រើការជាមួយប្រសិទ្ធភាព ហ្វាយនែន នៅខែមេសា ឆ្នាំ២០១៤ ជានាយកហិរញ្ញវត្ថុ បន្ទាប់មក លោកត្រូវបានដំឡើងតួនាទីទៅជាអគ្គនាយកផ្នែកហិរញ្ញវត្ថុនៅខែកក្កដា ឆ្នាំ២០១៤។ លោកធ្លាប់មានបទពិសោធធ្វើការងារជាបុគ្គលិករដ្ឋបាលនៅសាកលវិទ្យាល័យ វ៉ែនឡែន ឆ្នាំ២០០៣ ដល់ ២០០៥។ គណនេយ្យករ នៅអង្គការបន្ទាយស្រី ខេត្តបាត់ដំបង ឆ្នាំ២០០៧ ដល់ ២០០៨។ ជានាយករងធនធានមនុស្ស និងប្រភពទុន (Fund Manager) នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា ឆ្នាំ២០០៩ ដល់ ២០១៣។ លោកក៏មានបទពិសោធធ្វើការងារគម្រោងខ្លីៗ ដូចជា សវនករទ្រព្យសកម្ម សហគមន៍ ជាមួយអង្គការការីតាស បាត់ដំបង ជាសមាជិកក្រុមវាយតម្លៃឥទ្ធិពលនៃការអនុត្តន៍គម្រោង របស់សហព័ន្ធសហគមន៍សន្សំប្រាក់កម្ពុជា (CCSF) ជាសមាជិកសិក្សាគម្រោង ស្ដីអំពីលទ្ធភាពនៃការលក់ផលិតផលប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដោយជំពាក់ ជាសមាជិកសវនករឯករាជ្យអង្គការ Seva និងជាសាស្ត្រាចារ្យសកលវិទ្យាល័យបាត់ដំបង និងសាកលវិទ្យាល័យបៀលប្រាយ។



## លោក **ជា សុខលីម**
មន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់

បានចូលបម្រើការងារនៅ ប្រសិទ្ធភាព ហ្វាយនែន ក្នុងខែធ្នូ ឆ្នាំ២០១៤ ជាមន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់។ មុនពេលដែលលោកចូលរួមជាមួយប្រសិទ្ធភាព ហ្វាយនែន លោកបានធ្វើការ ឱ្យក្រុមហ៊ុនមួយដែលផ្ដល់សេវាកម្មផ្នែកបច្ចេកវិទ្យា ទៅអោយក្រុមហ៊ុនផ្សេងទៀតក្នុងនាមជា Server & storage engineer អស់រយៈពេល៥ឆ្នាំកន្លះ។ លោកបានទទួលបរិញ្ញាបត្រផ្នែកគ្រប់គ្រងផ្នែកព័ត៌មានវិទ្យានៅឆ្នាំ២០១០។



## លោក **ហេង តុលា**

### ជាប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល

លោកបានចូលរួមធ្វើកាជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ដែលមានតួនាទី ជាប្រធានមន្ត្រីឥណទាន និងបន្ទាប់មកលោកត្រូវបានដំឡើងឋានៈជាប្រធានគ្រប់គ្រងសាខាក្នុងភ្នំពេញ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤ ហើយបន្ទាប់មកបានដំឡើងឋានៈជាប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាលនៅការិយាកណ្តាល នៅថ្ងៃទី០៣ ខែមិឧសភា ឆ្នាំ២០១៦។ លោកធ្លាប់បានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សិលានិធិ ជាមន្ត្រីឥណទាន ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។ លោកទទួលបានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យបៀលប្រាយ លោកបានបញ្ចប់ដោយជោគជ័យ វគ្គបណ្តុះបណ្តាល ជាក់លាក់ និងសិក្ខាសាលា ដូចជា ប្រសិទ្ធភាពការគ្រប់គ្រងមនុស្ស ប្រសិទ្ធភាពការគ្រប់គ្រងសាខា ប្រសិទ្ធភាពការគ្រប់គ្រង និងការងាររដ្ឋបាល។



## លោក **ទ៊ឹយ ធី**

### ជាប្រធានផ្នែកឥណទាន

លោកបានចូលរួមធ្វើការជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ដែលមានតួនាទី ជាប្រធានសាខាបាទី ហើយបន្ទាប់មកបានដំឡើងឋានៈជាប្រធានផ្នែកឥណទាននៅការិយាកណ្តាល នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦។ លោកធ្លាប់បានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត ក្នុងមុខតំណែងជាច្រើន ដូចជា ជាមន្ត្រីឥណទាន ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ ជាមន្ត្រីឥណទានខ្នាតមធ្យម និងធំ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣ និងជាមន្ត្រីឥណទាន SME Loan និងជាអ្នកដឹកនាំមន្ត្រីឥណទានពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤។ លោកទទួលបានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យបៀលប្រាយ ពីឆ្នាំ២០១០ និងបញ្ចប់ថ្នាក់អនុបណ្ឌិតក្នុងឆ្នាំ ២០១៦ លោកបានបញ្ចប់ដោយជោគជ័យវគ្គបណ្តុះបណ្តាល ប្រសិទ្ធភាពការគ្រប់គ្រងសាខានៅធនាគា អេស៊ីលីដា ក្នុងឆ្នាំ២០១៥ ផងដែ។



## លោកស្រី **ប៊ួន ច័ន្ទសុភា**
ប្រធានគណនេយ្យករ

លោកស្រីបានបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យនៅឆ្នាំ ២០០៦។ ក្នុងចន្លោះពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥ លោកស្រីបានបម្រើការងារនៅក្នុងអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា មជ្ឈមណ្ឌលធនធានមនុស្សសម្រាប់ទីក្រុង។ បន្ទាប់ពីនោះមក ក្នុងឆ្នាំ២០០៧ លោកស្រីក៏បានផ្លាស់ប្តូរមកបំពេញការងារជាបុគ្គលិកនៅក្នុងវិស័យធនាគារវិញ គឺធនាគារអេស៊ីលីដា សាខាស្រុកចំការលើ ជាគណនេយ្យករ អស់រយៈពេល៩ឆ្នាំ។ លោកស្រីបានចូលរួមជាមួយនឹងប្រសិទ្ធភាព ហ្វាយនែន ចាប់តាំងពី ខែឧសភា ឆ្នាំ២០១៦ ក្នុងមុខតំណែងជាប្រធានគណនេយ្យករ។



## លោក **មិន វណ្ណរិទ្ធ**
ជាមន្ត្រីគាំទ្រសាខាជាន់ខ្ពស់

លោកបានចូលធ្វើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី នៅខែវិច្ឆិកា ឆ្នាំ២០១៤ ជាគណនេយ្យករ បន្ទាប់មកត្រូវបានដំឡើងតួនាទីជាមន្ត្រី គាំទ្រសាខានៅខែកុម្ភៈ ឆ្នាំ២០១៥ និងដំឡើងតួនាទីជាមន្ត្រីគាំទ្រសាខាជាន់ខ្ពស់នៅខែមករា ឆ្នាំ២០១៦។ លោកធ្លាប់ធ្វើការនៅក្នុងសមាគមន៍ស៊ីឌីអេ ជាមន្ត្រីហិរញ្ញវត្ថុចាប់ពីខែមិថុនា ឆ្នាំ២០១២ រហូតដល់ខែតុលា ឆ្នាំ ២០១៤។ លោកធ្លាប់ធ្វើជាគណនេយ្យករនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ចាប់ពីខែមិថុនា ឆ្នាំ២០១១ រហូតដល់ខែមិថុនា ឆ្នាំ២០១២ និងជាបេឡាករ ចាប់ពីខែមិថុនា ឆ្នាំ២០០៩ រហូតដល់ខែឧសភា ឆ្នាំ២០១១។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងជំនាញគណនេយ្យ នៅសាកលវិទ្យាល័យជា ស៊ីម កំចាយមារ នៅក្នុងឆ្នាំ២០០៩ និងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្មជំនាញហិរញ្ញវត្ថុ និងធនាគារនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០១៥។

# រចនាសម្ព័ន្ធគ្រប់គ្រង



# សូចនករសំខាន់ៗ

ចំណាត់ថ្នាក់ឥណទានតាមយេនឌ័រ




| អ្នកខ្ចី | គិតជាភាគរយ |
|---|---|
| បុរស | ៣៦% |
| ស្ត្រី | ៦៤% |
| សរុប | ១០០% |
| | |
| | |
| | |
| | |




## ចំណាត់ថ្នាក់តាមប្រភេទឥណទាន



| ប្រភេទឥណទាន | ចំនួនគណនេយ្យ | % |
|---|---|---|
| វិស័យកសិកម្ម | ១២២ | ១០.៨០% |
| ការជួញដូរ និងពាណិជ្ជកម្ម | ១៩៥ | ១៧.២៦% |
| សេវាកម្ម | ១៨ | ១.៥៩% |
| វិស័យដឹកជញ្ជូន | ២៣ | ២.០៤% |
| វិស័យសំណង់ | ៦៣ | ៥.៥៨% |
| ការប្រើប្រាស់ក្នុងគ្រួសារ | ៦៨១ | ៦០.២៧% |
| ប្រភេទឥណទានផ្សេងៗ | ២៨ | ២.៤៨% |
| **សរុប** | ១,១៣០ | ១០០.០០% |




| ឆ្នាំ | ចំនួនគិតជាប្រាក់ដុល្លារ |
|---|---|
| ២០១៣ | ៩៣៤,៣៤៧.០០ |
| ២០១៤ | ២,០២០,១១៦.០០ |
| ២០១៥ | ៣,៣៣៣,២២៩.០០ |
| ២០១៦ | ២,៨៦៨,៦៥៨.០០ |




| ផលចំណេញធៀបនឹងទ្រព្យសកម្ម | |
|---|---|
| ២០១៤ | ៥.២០% |
| ២០១៥ | ៦.១០% |
| ២០១៦ | ៣.០០% |




| ផលចំណេញធៀបនឹងដើមទុន | |
|---|---|
| ២០១៤ | ៥.៨០% |
| ២០១៥ | ៧.២០% |
| ២០១៦ | ៤.០០% |

# ការត្រួតពិនិត្យផ្ទៃក្នុង

ជាប្រព័ន្ធត្រួតពិនិត្យស្ថាប័នទាំងមូលរួមទាំងផ្នែកហិរញ្ញវត្ថុ។ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើតឡើងដោយអ្នកគ្រប់គ្រង ដើម្បីប្រតិបត្តិនៅក្នុងស្ថាប័នឱ្យមានប្រសិទ្ធភាពការងារ និងដើម្បីជឿជាក់ថាបុគ្គលិកប្រកាន់ខ្ជាប់នូវគោលការណ៍ របស់ស្ថាប័នថៃរក្សានូវទ្រព្យសម្បត្តិរបស់ស្ថាប័ន និងសុវត្ថិភាពនៃទិន្នន័យ។

គោលបំណងសំខាន់នៃការត្រួតពិនិត្យផ្ទៃក្នុងរបស់យើង ត្រូវបានកំណត់ដោយពាក្យមួយដើម្បីឱ្យមានភាពងាយស្រួលក្នុង ការចងចាំគឺ "CARES" ហើយត្រូវបានបកស្រាយដូចខាងក្រោម៖

- Compliance with applicable laws and policies
  គោរពទៅតាមច្បាប់ និងគោលការណ៍ផ្សេងៗដែលបាន ដាក់ឱ្យអនុវត្តន៍
- Accomplishment of the organization's mission and vision
  សម្រេចឱ្យបាននូវបេសកកម្ម និងទស្សនវិស័យរបស់ស្ថាប័ន
- Relevant and reliable data
  ព័ត៌មានត្រូវជាមួយនឹងស្ថានភាព និងអាចទុកចិត្តបាន
- Economical and efficient use of resources
  សន្សំសំចៃខ្ពស់ និងប្រសិទ្ធភាពក្នុងការប្រើប្រាស់នូវធនធាន
- Safeguard assets
  ការពារនូវទ្រព្យសម្បត្តិរបស់ស្ថាប័ន

# អតិថិជន និង និន្នាការសេដ្ឋកិច្ចសង្គម

## ការបញ្ជាក់ពីអតិថិជន



កាលពីអំឡុងឆ្នាំ២០១០ គាត់ជាជាងច្នៃត្បូងម្នាក់ដែលមានម៉ូយប្រហែលជា១០នាក់ មកទទួលទិញត្បូងពីគាត់ដើម្បីយកទៅលក់បន្ត គ្រានោះដែរគាត់ក៏នឹកចង់ពង្រីកមុខរបររបស់គាត់ឱ្យកាន់តែធំ តាមរយៈការទិញបន្ថែមនូវម៉ាស៊ីន និងឧបករណ៍ច្នៃត្បូង តែប្រាក់របស់លោកមានការខ្វះខាតបន្តិចបន្តួច ក្រោយមកលោកក៏បាននឹកឃើញដល់សេវាប្រាក់កម្ចីរបស់ប្រសិទ្ធភាព ហ្វាយនែន ដែលបុគ្គលិករបស់ ប្រសិទ្ធភាព ហ្វាយនែន ធ្លាប់បានទៅផ្តល់ព័ត៌មានជូនលោកកាលពីប៉ុន្មានខែមុន។ លោកបានសម្រេចចិត្តទំនាក់ទំនងមកខាងបុគ្គលិកភ្នាក់ងារឥណទានរបស់ប្រសិទ្ធភាព ហ្វាយនែន ដែលពេលនោះលោកមានតម្រូវការត្រឹមតែ ១៥០០ដុល្លារ តែប៉ុណ្ណោះ។ បន្ទាប់ពីទទួលបានប្រាក់កម្ចី រូបលោកក៏បានយកប្រាក់កម្ចីទាំងនោះទៅប្រើប្រាស់ទិញឧបករណ៍ច្នៃត្បូងបន្ថែម និងសល់មួយចំនួនយកទៅទិញត្បូងដែលមានប្រភពមកពីខេត្តរតនគិរីដើម្បីយកមកច្នៃសំរាប់លក់។ គាត់ក៏បានថ្លែងអំណរគុណដល់ប្រសិទ្ធភាពហិរញ្ញវត្ថុ ដែលបានផ្តល់ប្រាក់កម្ចីដល់គាត់ ដែលជួយសម្រួលដល់ការប្រកបមុខរបររបស់គាត់ ឱ្យកាន់តែប្រសើរ និងរីកចម្រើនជាងមុន។

**ឆម សារឿន**

អាជីវករច្នៃត្បូង



# ញឹម តុលា

អាជីវករលក់ទូរសព្ទដៃ

រូបលោកជាអាជីវករលក់ទូរសព្ទដៃ និងគ្រឿងបន្លាស់ហើយក៏ជាជាងជួសជុលទូរសព្ទដៃដែរ។ កាលពីអំឡុងឆ្នាំ២០១០ ជារៀងរាល់ថ្ងៃហាងលោកទទួលបានអតិថិជនជាហូរហែ ដែលអ្នកខ្លះចូលមកទិញគ្រឿងទូរសព្ទ និងអ្នកខ្លះយកទូរសព្ទមកឱ្យរូបលោកជួសជុល តែនពេលនោះហាងរបស់លោកនៅតូច និងមានទូរសព្ទលក់ត្រឹមតែប៉ុន្មានគ្រឿងប៉ុណ្ណោះ ដែលជាហេតុធ្វើឱ្យលោកគិតដល់រឿងប្រមូលដើមទុនក្នុងការទិញទូរសព្ទដាក់លក់បន្ថែម។ ក្រោយមកលោកក៏បានជួបពិភាក្សាជាមួយបងស្រីរបស់លោក ដែលធ្លាប់ទទួលបានសេវាប្រាក់កម្ចីពីខាងប្រសិទ្ធភាពហ្វាយនែន។ បងស្រីរបស់លោកបានប្រាប់លោកថាការទទួលបានបាក្រ់កម្ចី និងមានលក្ខខណ្ឌសមរម្យ។ តាមរយៈប្រាក់កម្ចីឥណទានចំនួន៣០០០ដុល្លារ របស់ប្រសិទ្ធភាពហ្វាយនែន នៅពេលនេះហាងលក់ទូរសព្ទរបស់លោកឃើញថាមានសភាពរីកចម្រើនជាងមុន ដោយមានការដាក់តាំងលក់ទូរសព្ទដៃនិងគ្រឿងទូរសព្ទកាន់តែច្រើនឡើងៗ៕



# ជា ថា

អាជីវករលក់ម៉ូតូ

លោកមានអាជីពជាជាងជួសជុលម៉ូតូ និងទិញលក់ម៉ូតូមួយទឹក។ ក្នុងឆ្នាំ២០១៣ ជាឆ្នាំដែលលោកបានចាប់ផ្តើមពិភាក្សាគ្នាជាមួយភរិយារបស់លោកក្នុងការដែលអ្នកទាំងពីរមានគម្រោងចង់រកប្រាក់កម្ចី ដើម្បីយកមកពង្រីកដើមទុនក្នុងមុខរបរដោយសារតែការមើលឃើញអំពីភាពរីកចម្រើនដែលលោកកាន់តែទទួលបានអតិថិជនច្រើនឡើងដែលត្រូវការរកទិញម៉ូតូមួយទឹកពីលោក។ ស្របគ្នានោះដែរ អ្នកទាំងពីរ ក៏នឹកឃើញដល់គ្រឹះស្ថានមីក្រូហិរញ្ញប្រសិទ្ធភាព ហ្វាយនែន ដោយសារតែធ្លាប់មានភ្នាក់ងាររបស់ប្រសិទ្ធភាព ហ្វាយនែន ធ្លាប់បានចុះមកផ្តល់ព័ត៌មានពីសេវាកម្មប្រាក់កម្ចីដល់ផ្ទះរបស់លោកកាលពីមុនមក។ លោកបានសម្រេចចិត្តស្នើប្រាក់កម្ចីមកកាន់ ប្រសិទ្ធភាព ហ្វាយនែនចំនួន ១៥,០០០ដុល្លារ។ ក្រោយការសិក្សាវាយតម្លៃរួចរាល់ ហើយឃើញថាគាត់អាចបំពេញតាមលក្ខខ័ណ្ឌគ្រប់គ្រាន់ ដែលអាចទទួលបានទំហំប្រាក់កម្ចីតាមការស្នើសុំបាន។ មកទល់បច្ចុប្បន្ននេះ យើងឃើញថាមុខរបររបស់លោកមានការរីកលូតលាស់ជាងមុន។

# និន្នាការសេដ្ឋកិច្ចសង្គម



សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែធ្នូ ឆ្នាំ២០១៦ បានកើនឡើង ០,៤% ធៀបនឹងខែមុន ឬ ៣,៩% ធៀបនឹង ១២ខែមុន។ ក្នុងខែធ្នូ ឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួនបានកើនឡើងគួរកត់សម្គាល់ មានអាហារ និង ភេស្ជៈ មិនមែនជាតិស្រវឹង និងភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់។ អតិផរណាមធ្យមប្រចាំ ឆ្នាំ២០១៦ មានអត្រា ៣,០% ខ្ពស់ជាងឆ្នាំ២០១៥ ដែលមានអត្រា ១,២%។ ការកើនអត្រាអតិផរណានេះ គឺដោយសារកំណើនថ្លៃម្ហូបអាហារ ជាពិសេសថ្លៃសាច់គោ សាច់មាន់ សាច់ជ្រូក និងត្រីស្រស់ស្របពេលនឹងមានការកើនឡើងថ្លៃអាហារសកល, កំណើន ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ បន្ទាប់ពីការកែសម្រួលអត្រាពន្ធអាករពិសេសលើមុខទំនិញនេះ និងកំណើន ថ្លៃសម្លៀកបំពាក់ និងស្បែកជើងដោយសារកំណើនថ្លៃវត្ថុធាតុដើមផលិតសម្លៀកបំពាក់។

គិតត្រឹមចុងឆ្នាំ២០១៦ ក្នុងវិស័យធនាគារកម្ពុជាមាន ៣៦ធនាគារពាណិជ្ជ ១៤ធនាគារឯកទេស និង ៦៦ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ (ក្នុងនោះទទួលប្រាក់បញ្ញើមាន ០៧គ្រឹះស្ថាន)។ ក្នុងរយៈពេល៥ឆ្នាំ ២០១១-២០១៥ ឥណទានផ្តល់ដោយ ធនាគារពាណិជ្ជមានកំណើនជាមធ្យម ២៩,៥% ក្នុងមួយឆ្នាំ ប៉ុន្តែកំណើននេះបានថយចុះមកត្រឹម ១៩% ក្នុងឆ្នាំ២០១៦។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៦ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជមានប្រមាណ ៥៧.០៣៥ ពាន់លានរៀល ក្នុងនោះ

ចំណែកនៃឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមាន ៨២,១% ឥណទានផ្តល់ដល់ គ្រឹះស្ថានហិរញ្ញវត្ថុមាន ១,៧% និងឥណទានដល់រូបវន្តបុគ្គលនិងផ្សេងៗមាន ១៦,២%។

ក្នុងឆ្នាំ២០១៦ ទំហំពាណិជ្ជកម្មរបស់កម្ពុជាមានការថមថយកំណើន ការនាំចូលសរុបជាទឹកប្រាក់មាន ១២.២៤២ លានដុល្លារ បានកើនឡើង ៥,៣% (២០១៥ កើន ១២,៨%) និងការនាំចេញសរុបមាន ១០.១៨៤ លានដុល្លារ បានកើនឡើង ១០% (២០១៥កើន ១៤,២%)។ កម្ពុជាមានប្រជាជនតិច ជាសេដ្ឋកិច្ចតូច និងកំពុងអភិវឌ្ឍមានការអាស្រ័យលើពាណិជ្ជកម្មអន្តរជាតិ ក្នុងការអូសទាញកំណើនសេដ្ឋកិច្ចទាំងមូល។

សម្រាប់ឆ្នាំ២០១៦ មុខទំនិញនាំចេញសំខាន់ៗ មានផលិតផលកាត់ដេរនិងស្បែកជើង (ប្រមាណ ៧៣% នៃការនាំចេញសរុប) នាំចេញទៅកាន់អឺរ៉ុប (៤៣%) សហរដ្ឋអាមេរិក (២៩,៤%) ជប៉ុន (៧,៦%) និង តំបន់ផ្សេងៗទៀត (២០%), ផលិតផលអង្ករនាំចេញទៅប្រទេសបារាំង និងម៉ូណាកូ (១៧,៩%) ចិន (១៤,៦%) ម៉ាឡេស៊ី (១៣,០%) ប៉ូឡូញ និងហូឡង់ដ៍ (១៥,៦%) ប្រទេសសហគមន៍អឺរ៉ុបផ្សេងៗ (១៩%) និងតំបន់ផ្សេងៗទៀត (១៩,៩%), ផលិតផលកៅស៊ូនាំចេញទៅប្រទេសចិន (២៩,៦%) វៀតណាម (១៩,៨%) ហុងកុង និងអាមេរិក (២១,៨%) ម៉ាឡេស៊ី និងជប៉ុន (១៥,១%) និងតំបន់ផ្សេងៗទៀត (១៣,៧%)។ ទីផ្សារដែលជាគោលដៅនាំចេញនៅមានលក្ខណៈប្រមូលផ្តុំនៅតំបន់អឺរ៉ុប និងសហរដ្ឋអាមេរិកនៅឡើយទោះបីជាមានពិពិធកម្ម និងឈានទៅកាន់ទីផ្សារថ្មីៗបន្ថែមទៀតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី។

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១៦*

# របាយការណ៍ហិរញ្ញវត្ថុ


- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ............................ ៣០
- របាយការណ៍របស់សវនករឯករាជ្យ ............................ ៣៧
- តារាងតុល្យការ ........................................................ ៤២
- របាយការណ៍លទ្ធផល ............................................... ៤៤
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន.......................... ៤៥
- របាយការណ៍លំហូរទឹកប្រាក់ ..................................... ៤៦

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងដល់ក្រុមគ្រួសារចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទពី ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានដូចខាងក្រោម៖

សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានដូចខាងក្រោម៖

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ចំណេញមុនដកពន្ធ | ១៤៧,០៦០ | ៥៩៣,៦៨២ |
| ពន្ធលើប្រាក់ចំណេញ | (២៨,៨៧៨) | (១១៦,៥៨០) |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | **១១៨,១៨២** | **៤៧៧,១០២** |

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភក្នុងការិយបរិច្ឆេទ ហើយក្រុមប្រឹក្សាភិបាលក៏មិនបានស្នើឲ្យមានការបង់ភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

ដើមទុនដែលបានចុះបញ្ជីរបស់ក្រុមហ៊ុនមានចំនួន ១,000,000 ដុល្លារអាមេរិក បែងចែកជា ១,000,000 (មួយលាន) ភាគហ៊ុន ដែលក្នុងមួយភាគហ៊ុនមានតម្លៃ មួយដុល្លារអាមេរិក។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា បានអនុម័តទៅលើសំណើសុំរបស់ក្រុមហ៊ុនចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីផែនការបង្កើនដើមទុន និងរចនាសម្ព័ន្ធភាគហ៊ុនរបស់ក្រុមហ៊ុនដូចខាងក្រោមនេះ៖

- បង្កើនដើមទុនពី ១,000,000 ដុល្លារអាមេរិក ទៅ ចំនួន ២,៩១៥,៧៦៦ ដុល្លារអាមេរិក (តាមរយៈការផ្ទេរគណនីដើមទុនផ្សេងៗ ចំនួន ១,៣១៥,៧៦៦ ដុល្លារអាមេរិក និងការដាក់ទុនបន្ថែមចំនួន ៦00,000 ដុល្លារអាមេរិក នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧) និងធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនដើម្បីឆ្លុះបញ្ចាំងពីការបង្កើនដើមទុននេះ និង
- ការកែសម្រួលលើលក្ខន្តិកៈ របស់ក្រុមហ៊ុនចំពោះដើមទុនថ្មីត្រូវបានទទួលយល់ព្រមដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ។

ក្រុមហ៊ុនបាននិងកំពុងដំណើរការសុំការទទួលស្គាល់លើការបង្កើនដើមទុនទាំងនេះ ពីក្រសួងពាណិជ្ជកម្មនាថ្ងៃចេញរបាយការណ៍នេះ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទាន ដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ឥណទាន ដែលជាប់សង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនាំឲ្យឥណទានអាក្រក់ដែលបានជំរះចេញពីបញ្ជី ឬចំនួនសំវិធានធនជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ក្រៅពីឥណទានដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការ អាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។ នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ក្រៅអំពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាលមានមតិថាពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវសង ឬអាចនឹងត្រូវសងក្នុងរយៈពេល ១២ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់ លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ការផ្លាស់ប្តូរហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរៃកញ្ញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរបាយការណ៍

នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ ធ៧-០១៧-១០៩ ប្រ.ក ដើម្បីកម្រិតអត្រាការប្រាក់អតិបរមាត្រឹម១៨%ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំងឥណទានរៀបចំឡើងវិញ និង/ ឬបុនហិរញ្ញប្បទានដោយមានចុះហត្ថលេខា និង/ឬស្នាមផ្តិតម្រាមដៃចាប់ពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៧ ។ នាថ្ងៃចេញរបាយការណ៍នេះឥណទានទាំងអស់របស់ក្រុមហ៊ុនត្រូវបានគិតតាមអត្រាការប្រាក់លើសពី ១៨% ក្នុងមួយឆ្នាំ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក លាក់ វាសនា | អភិបាល |
| លោក កែវ ឡង់ឌី | អភិបាលឯករាជ្យ |
| លោក កង ហេមជន្ទ | អភិបាលឯករាជ្យ |
| លោក សួស សុវណ្ណ | អភិបាលឯករាជ្យ |
| លោក ម៉ុក ណាច | អភិបាល |
| លោក គឹម ទេវិន្ទ្រ | អភិបាល (លាឈប់នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល
ក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅចុងការិយបរិច្ឆេទ និងមានភាគហ៊ុនកាន់កាប់របស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ២០១៦ | |
|---|---|---|
| | % នៃភាគហ៊ុន កាន់កាប់ | ចំនួនភាគហ៊ុន ១ ដុល្លារអាមេរិក ក្នុង ១ ភាគហ៊ុន |
| ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ៩៤.៩២ | ៩៤៩,២០០ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល
នៅក្នុងនិងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ
ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមមហ៊ុន) ដល់ ៣១ ខែធ្នូ ឆ្នាំ២០១៦។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ii) អនុវត្តទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញ

នូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(iv) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(v) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាភិបាលធានាអះអាងថាបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលសូមធានាអះអាងថា បានបំពេញនិងអនុវត្តនូវរាល់ការទទួលខុសត្រូវដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ខ្ញុំសូមអនុម័តរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅទំព័រទី១១ ដល់ទី៥៣ បានបង្ហាញនូវភាពត្រឹមត្រូវជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមមហ៊ុន) ដល់ ៣១ ខែធ្នូ ឆ្នាំ២០១៦ ។ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលៈ*

**ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី**
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី28 ខែមេសា ឆ្នាំ2017

**ម៉ុក ណាច**
អគ្គនាយក

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក
ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ របាយការណ៍លទ្ធផលរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងកំណត់សម្គាល់ដែលរួមមានសេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី ១១ ដល់ ៥៣។

ជាមតិរបស់យើងខ្ញុំ លើកលែងតែផលប៉ះពាល់ដែលអាចកើតមានដោយបញ្ហាដែលបានពណ៌នានៅកថាខ័ណ្ឌស្តីពីមូលដ្ឋាននៃមតិសវនកម្មមានបញ្ហានៃរបាយការណ៍នេះរបាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## មូលដ្ឋាននៃមតិសវនកម្មមានបញ្ហា

ដូចដែលបង្ហាញនៅក្នុងកំណត់សម្គាល់ ១៧ នៃរបាយការណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនបានកត់ត្រាចំណូលការប្រាក់បានពីឥណទានផ្តល់ដល់អតិថិជនចំនួន US$ ៥៣៨,៧០៧ (សមមូលនឹង២,១៧៤,៧៦០ ពាន់រៀល) សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយប្រើមូលដ្ឋានសាច់ប្រាក់ និងបង្គរួមបញ្ចូលគ្នាដោយសារតែប្រព័ន្ធកត់ត្រា និងតាមដានឥណទានរបស់ក្រុមហ៊ុននៅមានកម្រិត។ ការអនុវត្តនេះមិនបានអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមិនអាចកំណត់ចំនួនសម្រាប់ធ្វើនិយ័តកម្មលើរបាយការណ៍ហិរញ្ញវត្ថុបាន។ អាស្រ័យហេតុនេះយើងខ្ញុំមិនអាចកំណត់បានពីភាពត្រឹមត្រូវ ភាពកើតមានឡើងជាក់លាក់ ភាពពេញលេញនៃចំណូលការប្រាក់ និងការប្រាក់ត្រូវទទួល ដែលគួរកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយនីតិវិធី

សវនកម្មណាមួយទេ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងដែលស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមនៅក្នុងទំនួលខុសត្រូវរបស់សវនករសម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់សវនកម្ម។ យើងមានឯករាជ្យចំពោះក្រុមហ៊ុន ក្នុងការអនុលោមតាមលក្ខខណ្ឌតម្រូវតាមវិជ្ជាជីវៈដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវផ្សេងទៀតរបស់យើងនៅក្នុងវិជ្ជាជីវៈស្របតាមតម្រូវការទាំងនេះ។ យើងជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងទទួលបានគឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់នូវមូលដ្ឋាននៃមតិសវនកម្មមានបញ្ហារបស់យើង។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ៣០ ដល់ ៣៥ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថារួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចនៃរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន

ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។ អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមន្ទិលធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសម

ហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យរបស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌ ដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្ម ដែលប្រមូលបានត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។ យើងខ្ញុំផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាត នៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**




**ង៉ែ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧

# តារាងតុល្យការ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ | | ១៣,២៨៦ | ៥៣,៦៣៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិ | ៦ | ៥០,០៤៤ | ២០២,០២៨ |
| ប្រាក់បញ្ញើនៅធនាគារ | ៧ | ៧៩៤,៤០៨ | ៣,២០៧,០២៥ |
| ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ | ៨ | ២,៨៦៨,៦៥៨ | ១១,៥៨០,៧៧២ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ៨៩,៩៤៧ | ៣៦៣,១១៦ |
| ទ្រព្យ និងបរិក្ខារ | ១០ | ២៣,១៩១ | ៩៣,៦២២ |
| ទ្រព្យសកម្មអរូបិយ | ១១ | ៥,៧២០ | ២៣,០៩២ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១២ | ៥៣៤ | ២,១៥៦ |
| **សរុបទ្រព្យសកម្ម** | | ៣,៨៤៥,៧៨៨ | ១៥,៥២៥,៤៤៧ |
| **បំណុល និងមូលធន** | | | |
| **បំណុល** | | | |
| បំណុលផ្សេងៗ | ១៣ | ១២,៩៨៣ | ៥២,៤១៣ |
| ពន្ធលើប្រាក់ចំណេញត្រូវទូទាត់ | ១២ | ១១២,៨៣០ | ៤៥៥,៤៩៥ |
| ប្រាក់កម្ចី | ១៤ | ៤៣២,៩៤៩ | ១,៧៤៧,៨១៥ |
| **សរុបបំណុល** | | ៥៥៨,៧៦២ | ២,២៥៥,៧២៣ |

| | | | |
|---|---|---|---|
| **មូលធន** | | | |
| ដើមទុន | ១៥ | ១,០០០,០០០ | ៤,០៣៧,០០០ |
| បុព្វលាភភាគហ៊ុន | | ៦៣,០៧៨ | ២៥៤,៦៤៦ |
| ដើមទុនផ្សេងៗ | ១៦ | ២,១០៥,៧៦៦ | ៨,៥០០,៩៧៧ |
| ទុនបម្រុងតាមច្បាប់ | | ៥,៩០៩ | ២៣,៨៥៥ |
| ប្រាក់ចំណេញរក្សាទុក | | ១១២,២៧៣ | ៤៥៣,២៤៦ |
| **សរុបមូលធន** | | ៣,២៨៧,០២៦ | ១៣,២៦៩,៧២៤ |
| **សរុបបំណុល និងមូលធន** | | ៣,៨៤៥,៧៨៨ | ១៥,៥២៥,៤៤៧ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លទ្ធផល

សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន)
ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទ ពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|
| ចំណូលពីការប្រាក់ | ១៧ | ៥៥៤,៣៩៥ | ២,២៣៨,០៩៣ |
| ចំណាយលើការប្រាក់ | | (៤៧,៣២៩) | (១៩១,០៦៧) |
| **ចំណូលពីការប្រាក់សុទ្ធ** | | ៥០៧,០៦៦ | ២,០៤៧,០២៦ |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | | ២,៣៧៤ | ៩,៥៨៤ |
| **ចំណេញពីប្រតិបត្តិការ** | | ៥០៩,៤៤០ | ២,០៥៦,៦១០ |
| សំវិធានធនលើឥណទាន | | | |
| អាក្រក់និងជាប់សង្ស័យ | ៨ | (១៦,៤៨៩) | (៦៦,៥៦៦) |
| ចំណាយរដ្ឋបាលទូទៅ | ១៨ | (៣៤៥,៨៩១) | (១,៣៩៦,៣៦២) |
| **ចំណេញមុនដកពន្ធ** | | ១៤៧,០៦០ | ៥៩៣,៦៨២ |
| ពន្ធលើប្រាក់ចំណេញ | ១២ | (២៨,៨៧៨) | (១១៦,៥៨០) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | ១១៨,១៨២ | ៤៧៧,១០២ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន)
ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | ដើមទុន ដុល្លារ អាមេរិក | បុព្វលាភ ដើមទុន ដុល្លារអាមេរិក | ដើមទុន ផ្សេងៗ ដុល្លារអាមេរិក | ទុនបម្រុង តាមច្បាប់ ដុល្លារអាមេរិក | ចំណេញ រក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| នាថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) | - | - | - | - | - | |
| ការកត់បញ្ចូលលើកដំបូង (កំណត់សម្គាល់ ៥ (ខ)) | ១,000,000 | ៦៥,១២២ | ២,០៨១,៤៤១ | - | - | ៣,១៤៦,៥៦៣ |
| ដើមទុនបន្ថែមក្នុងការិយបរិច្ឆេទ | - | ១,៩៨២ | ៤០,៤២៩ | - | - | ៤២,៤១១ |
| ដើមទុនដកចេញ | - | (៤,០២៦) | (១៦,១០៤) | - | - | (២០,១៣០) |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ១១៨,១៨២ | ១១៨,១៨២ |
| ការផ្ទេរ | - | - | - | ៥,៩០៩ | (៥,៩០៩០) | - |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ១,000,000 | ៦៣,០៧៨ | ២,១០៥,៧៦៦ | ៥,៩០៩ | ១១២,២៧៣ | ៣,២៨៧,០២៦ |
| (សមមូលជាពាន់រៀល) (កំណត់សម្គាល់ ៤) | ៤,០៣៧,000 | ២៥៤,៦៤៦ | ៨,៥០០,៩៧៧ | ២៣,៨៥៥ | ៤៥៣,២៤៦ | ១៣,២៦៩,៧២៤ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរទឹកប្រាក់

សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន)
ដល់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ (ថ្ងៃបង្កើតក្រុមហ៊ុន) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | | (២,៧០៣,១១៩) | (១០,៩១២,៤៩០) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (៣៣,៥០៦) | (១៣៥,២៦៤) |
| ការទិញទ្រព្យសកម្មអរូបិយ | | (៧,៤៣០) | (២៩,៩៩៥) |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | | (៥០,០០០) | (២០១,៨៥០) |
| ប្រាក់បញ្ញើនៅធនាគារ | | (៣០០,០០០) | (១,២១១,១០០) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | | (៣៩០,៩៣៦) | (១,៥៧៨,២០៩) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់ទទួលបានពីកម្ចី | | ៦៤៩,៩៤៥ | ២,៦២៣,៨២៨ |
| ការទូទាត់ប្រាក់កម្ចី | | (២១៦,៩៩៦) | (៨៧៦,០១៣) |
| ដើមទុនបានបង់ | | ១,០០០,០០០ | ៤,០៣៧,០០០ |

| | | | |
|---|---|---|---|
| ដើមទុនផ្សេងៗ | | ២,១០៥,៧៦៦ | ៨,៥០០,៩៧៧ |
| បុព្វលាភភាគហ៊ុន | | ៦៣,០៧៨ | ២៥៤,៦៤៦ |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | | ៣,៦០១,៧៩៣ | ១៤,៥៤០,៤៣៨ |
| **ការកើនឡើងសុទ្ធនូវ សាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ៥០៧,៧៣៨ | ២,០៤៩,៧៣៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | ២០ | ៥០៧,៧៣៨ | ២,០៤៩,៧៣៩ |

# អាសយដ្ឋានទាក់ទង
# ស្នាក់ការកណ្តាល និងសាខា

## ទីស្នាក់ការសាខាភ្នំពេញ

ផ្ទះលេខ ៧៨បេ ផ្លូវលេខ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទលើតុលេខៈ ០២៣ ៩៥៥ ៩៥៦
សារអេឡិចត្រូនិចៈ pnpbranch@prasethpheapfinance.com
គេហទំព័រៈ www.prasethpheapfinance.com

## ទីស្នាក់ការសាខាបាទី

ផ្លូវជាតិលេខ២ ភូមិសីហា ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ (ខាងជើងផ្សារចំបក់ចម្ងាយ ១០០ម៉ែត្រ)
ទូរសព្ទលើតុលេខៈ ០៣២ ៩០០ ៣៣៣
សារអេឡិចត្រូនិចៈ btibranch@prasethpheapfinance.com
គេហទំព័រៈ www.prasethpheapfinance.com



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ធនាគារជាតិ នៃ កម្ពុជា
National Bank of Cambodia

លេខ : ម.ហ-៧៣
No : M.F- 73

# អាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
# LICENSE TO CONDUCT MICROFINANCE BUSINESS

## ធនាគារជាតិនៃកម្ពុជា

អនុញ្ញាតឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី** ដែលមានទីស្នាក់ការកាំងនៅអគារលេខបេ៧៨ ផ្លូវ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី** ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាស បទបញ្ជា សារាចរណែនាំ ព្រមទាំងលក្ខខណ្ឌទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

ទេសាភិបាល

ជា.ចាន់តូ

- អាជ្ញាប័ណ្ណនេះ មានប្រសិទ្ធភាពរហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩
- អាជ្ញាប័ណ្ណនេះ ត្រូវបង្ហាញសាធារណជនគ្រប់ពេលវេលា

## THE NATIONAL BANK OF CAMBODIA

allows microfinance institution **PRASETHPHEAP FINANCE PLC.** to conduct business as microfinance institution with head office at #B78, Street 199, Sangkat Tumnob Tuek, Khan Chamkamorn, Phnom Penh.

Microfinance institution **PRASETHPHEAP FINANCE PLC.** shall abide by the Law on Banking and Financial Institutions and Prakas, regulations, circulars, and conditions prescribed by the National Bank of Cambodia.

Phnom Penh, 31 Aug , 2016

Governor

Signed and sealed.

- This license is valid until, 31 Aug 2019
- This license shall be displayed in public at all times.

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY
ឆ្នាំទី១៦ លេខ៤៣៩៤ ថ្ងៃអង្គារ ទី២៨ ខែមីនា ឆ្នាំ២០១៧

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន
MJQ
MENGLY J. QUACH EDUCATION
MAR 28 2017

# សម្ពោធសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង១ខ្នងចំណាយទឹកប្រាក់អស់១២ម៉ឺនដុល្លារ

ភ្នំពេញ ៖ អគារសិក្សា១ខ្នង២ជាន់៤បន្ទប់និងហេដ្ឋារចនាសម្ព័ន្ធនៃសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង ស្ថិតនៅភូមិទួលបេង ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាមបានសម្ពោធដាក់ឲ្យប្រើប្រាស់ដែលចំណាយទឹកប្រាក់អស់១២ម៉ឺនដុល្លារ។

លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាលនិងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ.គួច អេឌ្យូខេសិន បានថ្លែងក្នុងពិធីសម្ពោធកាលពីថ្ងៃទី២៧ខែមីនាថា ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការសិក្សាអប់រំ និងកាត់បន្ថយភាពក្រីក្រ លោកនិងក្រុមគ្រួសារបានសាងសង់នូវអគារសិក្សា១ខ្នង ២ជាន់ ៤បន្ទប់ផ្ទុសផុលនិងកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជូនជាអំណោយដល់សាលាបឋមសិក្សា គួច ម៉េងលី ទួលបេង ដែលសរុបជាទឹកប្រាក់អស់១២ម៉ឺនដុល្លារ។ លោកបន្តថា មូលហេតុដែលលោកសម្រេចចិត្តជួយឧបត្ថម្ភសាងសង់នូវអគារសិក្សានៅក្នុងភូមិនេះគឺដោយសារមើលឃើញនូវកង្វះខាតអគារសិក្សា និងជាចំណង់ចំណូលចិត្តផ្នែកវិស័យអប់រំរបស់លោកផ្ទាល់។ លោកឧកញ៉ាបន្តថា ការជួយនេះគឺជួយតាមតំបន់ដាច់ស្រយាល ជួយដូចជាថ្នាំពេទ្យ សាងសង់ស្ពាន និងសាងសង់អគារសិក្សានេះជាដើម ទៅតាមលទ្ធភាពដែលអាចជួយបាន។ លោកបន្តថា លោកនឹងសាងសង់សាលាសិក្សាទី៣ ដែលស្ថិតនៅក្នុងទឹកដីខេត្តបាត់ដំបង ដើម្បីចូលរួមពង្រឹងគ្រឹះនៃការសិក្សាអប់រំឲ្យមានគុណភាពកាន់តែប្រសើរឡើង។

គួរបញ្ជាក់ដែរថា សាលាបឋមសិក្សាគួច ម៉េងលី ទួលបេងនេះជាសាលាទី២ដែលបានកសាងឡើងដែលសាលាទី១បានដាក់សម្ពោធឲ្យប្រើប្រាស់នៅថ្ងៃទី០១ ខែ ឧសភា ឆ្នាំ ២០១០ ឈ្មោះថាសាលាបឋមសិក្សា គួច ប៉េងសាំង-ងិនហួយ នៅខេត្តកំពង់ឆ្នាំងដែលចំណាយទឹកប្រាក់អស់១០៣,០០០ដុល្លារ ហើយគម្រោង សាងសង់សាលាសិក្សាទី៣ស្ថិតនៅក្នុងទឹកដីខេត្តបាត់ដំបង។

នាយកសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង លោក សេងរី បានប្រាប់ឲ្យដឹងថា សាលានេះបានកសាងឡើងនៅឆ្នាំ១៩៨៦ ដោយសហគមន៍សង់អគារសិក្សា១ខ្នង ២បន្ទប់ សម្រាប់ធ្វើជាសាលាឆ្លងកាត់ គឺមាន២កម្រិតថ្នាក់ទី១ និងទី២ ហើយសាលានេះដំណើរការរហូតដល់ឆ្នាំ២០១០ត្រូវបានបិទទ្វារមួយរយៈ ដោយសាលានេះសិស្សមានចំនួនតិច។ លោកបន្តថា ក្នុងឆ្នាំ២០១២ -១៣ក៏ចាប់ផ្តើមដំណើរការឡើងវិញ ដោយមានការគាំទ្រផងពីខាងមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម ការិយាល័យអប់រំស្រុកកំពង់សៀម ហើយជាពិសេសមានអង្គការដៃគូ ធ្វើឲ្យសាលារបស់យើងទាំងអស់គ្នាចាប់ផ្តើមមានការកើនឡើងជាលំដាប់នៃចំនួនសិស្សចូលរៀន។

លោកបន្តថា ចំនួនសិស្សកើនឡើងខ្លាំងធ្វើឲ្យយើងប្រឈមនឹងការខ្វះខាតអគារសិក្សា ដោយឃើញបញ្ហាប្រឈមនេះទើបលោកឧកញ៉ាវេជ្ជបណ្ឌិត គួច ម៉េងលី លោកបានផ្តល់អគារតាមតម្រូវការរបស់យើង។

លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី បានបន្ថែមដោយផ្តាំផ្ញើដល់គណៈគ្រប់គ្រងសាលានិងសិស្សានុសិស្សទាំងអស់រួមគ្នាថែរក្សាទ្រព្យសម្បត្តិសាលាដែលដាក់ឲ្យសម្ពោធឲ្យប្រើប្រាស់នៅថ្ងៃនេះ និងទ្រព្យសម្បត្តិសាលាដែលមានស្រាប់ដើម្បីទុកជាប្រវត្តិសាស្ត្រនិងមរតកសម្រាប់សិស្សានុសិស្សជំនាន់ក្រោយៗទៀត។ ក្នុងឱកាសនោះដែរលោកឧកញ៉ាបានឧបត្ថម្ភកង់ ៦៦គ្រឿង កាតាប ២៦៨ ជូនសិស្សានុសិស្ស និងឧបត្ថម្ភថវិកាជូនប្រជាពលរដ្ឋ ២លានរៀលសម្រាប់រៀបចំកម្មវិធីបុណ្យភូមិ ដើម្បីអបអរសាទពិធីសម្ពោធសាលាបឋមសិក្សា គួច ម៉េងលី ទួលបេង នាពេលនេះ។ ពេជ្រ





លោកបណ្ឌិត គួច ម៉េងលី កាត់ខ្សែបូសម្ពោធអគារសិក្សា

MJQ
ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន

រស្មីកម្ពុជា ប្រចាំថ្ងៃ
#474, មហាវិថីព្រះនុរោត្តម, ភ្នំពេញ website: www.rasmeinews.com
RASMEI KAMPUCHEA DAILY NEWSPAPER
ឆ្នាំទី25 លេខ7292 ថ្ងៃអង្គារ ទី28 ខែមីនា ឆ្នាំ 2017 • ការិយាល័យគ្រប់គ្រង និងផ្សាយពាណិជ្ជកម្ម
TEL:023 726 655 Fax: 023 217 172 ការិយាល័យនិពន្ធ TEL: 023 224 605 តម្លៃ 1000 រៀល

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន
MJQ
MENGLY J. QUACH EDUCATION
MAR 28 2017

# សម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា ជាអំណោយរបស់ឧកញ៉ាគួច ម៉េងលី



លោកឧកញ៉ា គួច ម៉េងលី អញ្ជើញសម្ពោធអគារសិក្សានៅ សាលាបឋមសិក្សាគួច ម៉េងលី ទួលបេង

ដោយ : បញ្ញាសាស្ត្រ

**ភ្នំពេញ :** អគារសិក្សាមួយខ្នង កម្ពស់ពីរជាន់ មានបួនបន្ទប់ និងហេដ្ឋារចនាសម្ព័ន្ធនៃសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ កាលពីព្រឹកថ្ងៃទី២៧ មីនា ២០១៧ ក្រោមជំនួយរបស់ឧកញ៉ាវេជ្ជបណ្ឌិតគួចម៉េងលី ស្ថាបនិកប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុន ម៉េង លី ជេ គួច អេឌ្យូខេសិន និងមានការចូលរួមពីលោកហ៊ុន-ម៉េងស្រ៊ុ អនុប្រធានមន្ទីរអប់រំយុវជន

តទៅទំព័រ 36


MJQ
ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន

កោះសន្តិភាព ប្រចាំថ្ងៃ
KOH SANTEPHEAP DAILY
ទីចាត់ការលេខ : 165E0 វិថី 169 ខាងកើតបុរីកីឡា ការិយាល័យផ្សាយពាណិជ្ជកម្ម : (023) 98 71 18
ការិយាល័យនិពន្ធ : (023) 98 71 19, Fax : 98 71 17 & 22 01 55
ឆ្នាំទី 50 លេខ 9055 ចេញផ្សាយថ្ងៃ ពុធ ទី 29 ខែ មីនា ឆ្នាំ 2017 តម្លៃ ១.០០០ រៀល

ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន
MJQ
MENGLY J. QUACH EDUCATION
MAR 29 2017

# ពិធីសម្ពោធអគារសិក្សានៃសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង



*លោកឧកញ៉ាវេជ្ជបណ្ឌិតគួច ម៉េងលី កាត់ខ្សែ (រូបថត សហការី)*

**ខេត្តកំពង់ចាម** ៖ អគារសិក្សា១ខ្នងនៃសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង ធ្វើអំពីថ្មប្រក់ក្បឿង ស្ថិតនៅភូមិទួលបេង ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ត្រូវបានបើកសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការហើយ កាលពីថ្ងៃទី២៧ មីនា កន្លងមកនេះ ដោយបានការអញ្ជើញចូលរួមពីលោកឧកញ៉ាវេជ្ជបណ្ឌិតគួច ម៉េងលី ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុន ម៉េងលី ជេ

តទៅទំព័រ 15

ទំព័រ១ នៃ២
MJQ
MENGLY J. QUACH EDUCATION
ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន

ប្រសិទ្ធភាព ហ្វាយនែន

Prasethpheap Finance

## ទីស្នាក់ការកណ្តាល


ផ្ទះលេខ ៧៨បេ ផ្លូវលេខ ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន
រាជធានីភ្នំពេញ
ទូរសព្ទលើតុលេខ: ០២៣ ៩៥៥ ៥៥៦
សារអេឡិចត្រូនិច: pnpbranch@prasethpheapfinance.com
គេហទំព័រ: www.prasethpheapfinance.com